ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៣៣/១៧ គលៈឋ

# កំណត់ហេតុកិច្ចប្រជុំ
# ស្តីពីការពិនិត្យសម្រេចលើសេចក្តីព្រាងរបាយការណ៍ជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ២០១៦
## ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែមករា ថ្ងៃទីសាមសិបមួយ វេលាម៉ោងប្រាំបីព្រឹក នៅទីស្តីការក្រសួងមហាផ្ទៃ អគារ"ទ" មានបើកកិច្ចប្រជុំអន្តរក្រសួង ពិភាក្សា ពិនិត្យសម្រេចលើសេចក្តីព្រាងរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ២០១៦ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ** ។

សមាសភាពចូលរួមកិច្ចប្រជុំសរុបចំនួន **៧៣រូប** រួមមានតំណាងមកពី ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងផែនការ ក្រសួងមុខងារសាធារណៈ ក្រសួងអភិវឌ្ឍជនបទ ក្រសួងការងារ ក្រសួងការពារជាតិ ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងសង្គមកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍ ក្រសួងការបរទេស ទីស្តីការគណៈរដ្ឋមន្ត្រី អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អគ្គបញ្ជាការដ្ឋានខ.ភ.ម កងរាជអាវុធហត្ថផ្ទៃប្រទេស និងមហាអយ្យការសាលាឧទ្ធរណ៍ ។

គោលបំណងនៃកិច្ចប្រជុំគឺ ដើម្បីផ្ទៀងផ្ទាត់ កែសម្រួល និងពិនិត្យសម្រេចលើសេចក្តីព្រាងរបាយការណ៍ជាតិ ដើម្បីទទួលបានរបាយការណ៍ជាតិមួយដែលមានលក្ខណៈពេញលេញ និងសុក្រឹត ។

**កិច្ចប្រជុំបានប្រព្រឹត្តទៅដោយតំណាងក្រសួង-ស្ថាប័នសាមីធ្វើការផ្ទៀងផ្ទាត់ និងពិនិត្យមើលចំណុចរបស់ខ្លួននៅក្នុងពង្រាងរបាយការណ៍ ហើយបានចូលរួមយោបល់ កែសម្រួលនូវចំណុចខុសឆ្គង និងបំពេញនូវចំណុចខ្វះខាតមួយចំនួន ៖**

ក. មតិយោបល់ចូលរួម

**ឯកឧត្តម កើត រិទ្ធ រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌** ៖ គួរដាក់ចូលបញ្ច្រៀបច្បាប់ការថតសម្លេងគូសន្ទនាដែលចេញដោយក្រសួងទូរគមនាគមន៍ និងប្រៃសនីយ៍ ។

**លោក ព្រុំ សុខន ប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច** ៖ វគ្គបណ្តុះបណ្តាលទាំងអស់គួរប្រាប់បញ្ចូលគ្នាដើម្បីឲ្យមើលទៅឃើញខ្លី ។

**ឯកឧត្តម ណាត ប៊ុនរឿន រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា** ៖ អំពីទិដ្ឋភាពរួមលើទម្រង់របាយការណ៍ ដោយយុទ្ធសាស្ត្រមាន ៤ ដូចនេះគួររំលេចក្រសួងនាំមុខមុនគេ បន្ទាប់មកដាក់ក្រសួងពាក់ព័ន្ធ ។ ក្នុងចំណុចទី១ "ស្ថានភាពទូទៅ" គួរយកចំណុចវិជ្ជមានដាក់មុន រួចទើបចូលបញ្ហាជាក្រោយ ។ ក្នុងរបាយការណ៍

គួរប្រើពាក្យឲ្យដូចគ្នា (ឧទាហរណ៍៖ អនុស្សរណៈយោគយល់) កុំឲ្យកន្លែងខ្លះខ្វះពាក្យ កន្លែងខ្លះលើសពាក្យ។ ភាសាអង់គ្លេសបើសរសេរជាខ្មែរមើលយល់ គួរដាក់ជាភាសាខ្មែរ មិនបាច់ដាក់ភាសាអង់គ្លេសទេ ។

**លោកជំទាវ ឧ.ឯក យក់ សុខា អគ្គស្នងការរង អគ្គស្នងការដ្ឋាននគរបាលជាតិ ៖** សុំដាក់អគ្គស្នងការដ្ឋាននគរបាលជាតិនាំមុខនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស (យកស្ថាប័នជាគោល) ។

ខ. បញ្ហាប្រឈម និងកង្វះខាត

- តួលេខពលករចេញទៅក្រៅប្រទេសរបស់ក្រសួងការងារ និងតួលេខរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៅមិនទាន់ស៊ីសង្វាក់គ្នា ត្រូវការពិភាក្សាគ្នាបន្ត ។
- ទិន្នន័យ និងរបាយការណ៍នៅមិនទាន់គ្រប់គ្រាន់ និងត្រូវការកែសម្រួលខ្លះ ដែលស្ថាប័នសាមីនីមួយៗត្រឡប់ទៅវិញនឹងធ្វើការកែសម្រួល រួចបញ្ជូនមកអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ដើម្បីបញ្ចូលបន្ថែមឲ្យបានសព្វគ្រប់ជ្រុងជ្រោយ ។

**ជាទីបញ្ចប់ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ បានមានប្រសាសន៍ណែនាំអំពីការងារមួយចំនួនដូចខាងក្រោម៖**

- ការងារដែលបានធ្វើហើយដាក់ចូលមក បើមិនទាន់បានធ្វើទេដាក់ជាទិសដៅ ។
- បើមិនឃើញមានទិន្នន័យរបស់ខ្លួននៅក្នុងពង្រាងនេះ សូមបញ្ជូនមកថែមទៀត ។
- សូមយកទៅពិនិត្យបន្ថែម និងកែសម្រួលចំណុចខ្វះខាតរៀងៗខ្លួន រួចបញ្ជូនមក ។
- ដាក់ឲ្យចំការងារ សន្និដ្ឋាន និងទិសដៅរបស់ស្ថាប័នខ្លួនផ្ទាល់ ។
- ចំពោះអ្នកធ្វើរបាយការណ៍ "ទិសដៅ ក៏ត្រូវរៀបតាមយុទ្ធសាស្ត្រទាំង៤ដែរ" ។
- សូមប្រមូល និងបញ្ជូនទិន្នន័យមកត្រឹមថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៧ ។
- ទិន្នន័យទាំងនេះនឹងយកជាផ្លូវការ និងដាក់ជូនប្រមុខរាជរដ្ឋាភិបាល ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់មួយ និងសាមសិបនាទី ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**អ្នកកត់ត្រា**

ហ៊ុ. រតនៈ

គោរពជូន លោកជំទាវ

អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ២០១៧

**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ត្រី គង់ ពុទ្ធិ

បាទឃើញ

28/02/2017

ជូ ប៊ុនអេង

# សមាសភាពចូលរួមកិច្ចប្រជុំ
# ស្តីពីការពិនិត្យសម្រេចលើសេចក្តីព្រាងរបាយការណ៍ជាតិ
# ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ២០១៦
# ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧
# សរុបចំនួន ៧៣ រូប

| | | | |
|---|---|---|---|
| ១ - លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ | |
| ២ - ឯកឧត្តម | សៀង ឡាប្រេស្ស | ទីប្រឹក្សារាជរដ្ឋាភិបាល | ក្រសួងមហាផ្ទៃ |
| ៣ - ឯកឧត្តម | ណាត ប៊ុនរឿន | រដ្ឋលេខាធិការ | ក្រសួងអប់រំ យុវជន និងកីឡា |
| ៤ - ឯកឧត្តម | កើត រិទ្ធ | រដ្ឋលេខាធិការ | ក្រសួងយុត្តិធម៌ |
| ៥ - លោកជំទាវ | ប៉ែន សុបភា | រដ្ឋលេខាធិការ | ក្រសួងផែនការ |
| ៦ - លោកជំទាវ | វ៉ាន់ ម៉ារា | រដ្ឋលេខាធិការ | ក្រសួងមុខងារសាធារណៈ |
| ៧ - លោកជំទាវ | ម៉ាត់ ម៉ារ៉ា | រដ្ឋលេខាធិការ | ក្រសួងអភិវឌ្ឍជនបទ |
| ៨ - លោកជំទាវ | ដាំ ដារីនី | រដ្ឋលេខាធិការ | ក្រសួងការពារជាតិ |
| ៩ - លោកជំទាវ | ច័ន្ទ ធី | រដ្ឋលេខាធិការ | ក្រសួងព័ត៌មាន |
| ១០ - ឯកឧត្តម | ហ៊ូ វុឌ្ឍី | អនុរដ្ឋលេខាធិការ | ក្រសួងការងារ |
| ១១ - ឯកឧត្តម | ថាច់ កេត | អនុរដ្ឋលេខាធិការ | ក្រសួងព័ត៌មាន |
| ១២ - ឯកឧត្តម | គង់ កន្ធារ៉ា | អនុរដ្ឋលេខាធិការ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ១៣ - ឯកឧត្តម | អ៊ិន វិធុរៈ | អនុរដ្ឋលេខាធិការ | ក្រសួងសង្គមកិច្ច |
| ១៤ - លោកជំទាវ | កែវ ចរិយា | អនុរដ្ឋលេខាធិការ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១៥ - លោកជំទាវ | សួស រដ្ឋាវី | អនុរដ្ឋលេខាធិការ | ក្រសួងការងារ |
| ១៦ - លោកជំទាវ | សឿ សុជាតា | អនុរដ្ឋលេខាធិការ | ក្រសួងអប់រំ យុវជន និងកីឡា |
| ១៧ - លោកជំទាវ | យុន វ៉ារី | អនុរដ្ឋលេខាធិការ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| ១៨ - ឯកឧត្តម ឧ.ឯក | ប៉ោង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |
| ១៩ - ឯកឧត្តម | ប៉ែន ពេជ្រសាលី | អគ្គនាយក | ក្រសួងយុត្តិធម៌ |
| ២០ - ឯកឧត្តម | ពេញ វិបុល | ព្រះរាជអាជ្ញា និងជាអគ្គនាយករង | ក្រសួងយុត្តិធម៌ |
| ២១ - ឯកឧត្តម ឧ.ឯក | យុន សំបូរ | អគ្គនាយករង | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ២២ - លោកជំទាវ ឧ.ឯក | យក់ សុខា | អគ្គស្នងការរង | អគ្គស្នងការដ្ឋាននគរបាលជាតិ |
| ២៣ - ឯកឧត្តម | ប្រាក់ ច័ន្ទតារា | អគ្គនាយករង | ក្រសួងទេសចរណ៍ |
| ២៤ - ឯកឧត្តម | ឡាយ វុទ្ធី | អគ្គនាយករង | ក្រសួងប្រៃសណីយ៍ |
| ២៥ - ឯកឧត្តម ឧ.ឯក | ខៀវ ចាន់រ៉ា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ២៦ - ឯកឧត្តម ឧ.ទោ | អ៊ូ ម៉ានីរ៉ា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ២៧ - លោកជំទាវ ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ២៨ - ឯកឧត្តម ឧ.ឯក | ស៊ុន វ៉ូ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ២៩ - ឯកឧត្តម ឧ.ឯក | យឹម វិរៈ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៣០ - លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៣១ - ឯកឧត្តម ឧ.ទោ | យ៉ែម ច័ន្ទណារុំ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៣២ - ឯកឧត្តម ឧ.ឯក | ប៉ុល ភិជេយ្យ | ប្រធាននាយកដ្ឋាន | នា.ដ្ឋានប្រឆាំងការជួញដូរមនុស្ស |
| ៣៣ - លោក | សេង ពុទ្ធី | ប្រធាននាយកដ្ឋាន | ក្រសួងយុត្តិធម៌ |
| ៣៤ - លោកស្រី | ព្រុំ សុខន | ប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |

| | | | |
|---|---|---|---|
| ៣៥ - ឧត្តមសេនីយ៍ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៣៦ - ឧត្តមសេនីយ៍ត្រី | លី តុងហុយ | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៣៧ - វរសេនីយ៍ឯក | កែវ សុវណ្ណារ៉ា | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៣៨ - ឧត្តមសេនីយ៍ត្រី | សុខ រស្មី | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៣៩ - ឧត្តមសេនីយ៍ត្រី | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋានស្តីទី | គ.ជ.ប.ជ |
| ៤០ - លោក | តែ សុថារ៉េត | ប្រធាននាយកដ្ឋានស្តីទី | គ.ជ.ប.ជ |
| ៤១ - លោកស្រី | ឃិន សុគន្ធារី | ព្រះរាជអាជ្ញា | មហាអយ្យការសាលាឧទ្ធរណ៍ |
| ៤២ - លោក | ង៉ែត សារ៉ាត់ | ព្រះរាជអាជ្ញា | មហាអយ្យការសាលាឧទ្ធរណ៍ |
| ៤៣ - ឧត្តមសេនីយ៍ត្រី | សៅ ម៉ាឡៃ | អនុប្រធាននាយកដ្ឋានព្រំដែនគោក | អគ្គស្នងការដ្ឋាននគរបាលជាតិ |
| ៤៤ - ឧត្តមសេនីយ៍ត្រី | សួន សុជាតិ | អនុប្រធាននាយកដ្ឋាន | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ៤៥ - វរសេនីយ៍ទោ | អ៊ុន មាន | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៤៦ - វរសេនីយ៍ឯក | ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ៤៧ - លោក | ប៉ុណ្ណ ចន្ថា | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ៤៨ - វរសេនីយ៍ឯក | ថោង វុទ្ធី | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ៤៩ - លោក | ទូច ពណ្ណរាយ | អនុប្រធាននាយកដ្ឋាន | ក្រសួងការងារ |
| ៥០ - លោក | អ៊ឹង វណ្ណថា | អនុប្រធាននាយកដ្ឋាន | ក្រសួងការបរទេស |
| ៥១ - លោក | ជីន ចន | អនុប្រធាននាយកដ្ឋាន | ក្រសួងកិច្ចការនារី |
| ៥២ - លោកស្រី | កែវ ម៉ាលី | អនុប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| ៥៣ - វរសេនីយ៍ឯក | ហែម បូរ៉ា | ជំនួយការអគ្គលេខាធិការ | គ.ជ.ប.ជ |
| ៥៤ - ឧត្តមសេនីយ៍ទោ | ឈុន វឌ្ឍនៈ | នាយករងទីចាត់ការការងារព្រំដែន | អគ្គបញ្ជាការដ្ឋានខ.ភ.ម |
| ៥៥ - លោកស្រី | រាម នាវតី | នាយការិយាល័យ | ក្រសួងយុត្តិធម៌ |
| ៥៦ - លោក | ប៉ា ប៉ុណ្ណារ៉ាដា | នាយការិយាល័យ | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៥៧ - លោក | ឱុច សុគន្ធ | នាយការិយាល័យ | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៥៨ - វរសេនីយ៍ត្រី | អ៊ុន សុខដា | នាយការិយាល័យ | គ.ជ.ប.ជ |
| ៥៩ - វរៈសេនីយ៍ត្រី | ឯម សុជាតិ | នាយការិយាល័យ | គ.ជ.ប.ជ |
| ៦០ - វរសេនីយ៍ត្រី | ស្រី មករា | នាយរងការិយាល័យ | គ.ជ.ប.ជ |
| ៦១ - វរសេនីយ៍ត្រី | ជៀប នួច | នាយរងការិយាល័យ | គ.ជ.ប.ជ |
| ៦២ - វរសេនីយ៍ត្រី | ហ៊ី រតនៈ | នាយរងការិយាល័យ | គ.ជ.ប.ជ |
| ៦៣ - វរៈសេនីយ៍ត្រី | ផេង សេងលីម | នាយរងការិយាល័យ | គ.ជ.ប.ជ |
| ៦៤ - អនុសេនីយ៍ទោ | ថោង សុវត្ថិ | នាយរងការិយាល័យ | គ.ជ.ប.ជ |
| ៦៥ - លោក | ស សារុធ | នាយរងការិយាល័យ | កងរាជអាវុធហត្ថផ្ទៃប្រទេស |
| ៦៦ - លោក | ការប៊ុត សុមឡែន | នាយរងការិយាល័យ | ក្រសួងការងារ |
| ៦៧ - លោក | សេង សូវ៉ាត | នាយរងការិយាល័យ | ក្រសួងអប់រំ យុវជន និងកីឡា |
| ៦៨ - លោក | អ៊ុំ សារ៉េត | នាយរងការិយាល័យ | នា.ដ្ឋានប្រឆាំងការជួញដូរមនុស្ស |
| ៦៩ - លោក | ប៊ុត ស៊ីថា | នាយរងការិយាល័យ | នា.ដ្ឋានប្រឆាំងការជួញដូរមនុស្ស |
| ៧០ - លោកស្រី | ឯក សេដារី | ជំនួយការអគ្គនាយករង | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៧១ - លោក | ឈិត ចំរុង | មន្ត្រីការិយាល័យនីតិកម្ម | នាយកដ្ឋាននីតិកម្ម |
| ៧២ - លោក | ស្រី ចឹម | មន្ត្រីសមាហរណកម្ម | ក្រសួងសង្គមកិច្ច |
| ៧៣ - លោកស្រី | ឯម សិលា | មន្ត្រី | ក្រសួងសង្គមកិច្ច |